**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទិវាទេសចរណ៍ពិភពលោក នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ក្រោមប្រធានបទ "និរន្តរភាពទេសចរណ៍ ជាយន្តការសម្រាប់ការអភិវឌ្ឍន៍- Sustainable Tourism- a Tool for Development"

## នៅខេត្តកែប

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ!
- ជនរួមជាតិជាទីស្នេហា!

ខ្ញុំព្រះករុណាខ្ញុំ មានក្តីសោមនស្សបំផុតដោយបានចូលរួមជាមួយជនរួមជាតិ និងប្រជាជាតិនានានៅទូទាំងពិភពលោក ក្នុងឱកាសអបអរសាទរទិវាទេសចរណ៍ពិភពលោក នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ក្រោមប្រធានបទ **"និរន្តរភាពទេសចរណ៍-ជាយន្តការសម្រាប់ការអភិវឌ្ឍន៍ (Sustainable Tourism- a Tool for Development)"**។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ សូមវាយតម្លៃខ្ពស់ចំពោះអង្គការទេសចរណ៍ពិភពលោកដែលតែងយកចិត្តទុកដាក់ខ្ពស់លើការជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ពិភពលោក និងការលើកកម្ពស់តួនាទីដ៏សំខាន់នៃវិស័យទេសចរណ៍ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន។

ទិវាទេសចរណ៍ពិភពលោក ជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់សម្រាប់ជំរុញភាគីពាក់ព័ន្ធនានារួមមាន ផ្នែកសាធារណៈ ផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ អង្គការ ប្រជាពលរដ្ឋ និងទេសចរ ឲ្យកាន់តែយល់ច្បាស់អំពីតួនាទី និងអត្ថប្រយោជន៍នៃវិស័យទេសចរណ៍ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន។

រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា មានសេចក្តីរីករាយក្នុងការចូលរួមប្រារព្ធ **ទិវាទេសចរណ៍ពិភពលោកឆ្នាំ២០១៧** ជាមួយពិភពលោកទាំងមូល ហើយឆ្លៀតឱកាសនេះ ដើម្បីអបអរសាទរចំពោះសមិទ្ធផលទេសចរណ៍កម្ពុជា និងលើកទឹកចិត្តគ្រប់ភាគីពាក់ព័ន្ធ បន្តគាំទ្រការអភិវឌ្ឍទេសចរណ៍កម្ពុជា សំដៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិនៅឆ្នាំ២០៣០។

ជាក់ស្តែង **ទិវាទេសចរណ៍ពិភពលោកឆ្នាំ២០១៧** នៅក្នុងឆ្នាំនេះ និងប្រារព្ធធ្វើឡើងរួមជាមួយនឹងឆ្នាំអន្តរជាតិ២០១៧នៃការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព (2017 International Year of Sustainable Tourism for Development)។ ទិវានេះនឹងរៀបចំឡើងក្នុងគោលបំណងស្វែងរកការចូលរួមរបស់វិស័យទេសចរណ៍ទៅក្នុងគោលដៅការអភិវឌ្ឍប្រកបដោយនិរន្តរភាព (Sustainable Development Goals)។ ដោយឈរលើគោលការណ៍នៃការ **"មិនទុកបុគ្គលណាម្នាក់នៅពីក្រោយ - Leaving no one behind"** វិស័យទេសចរណ៍ត្រូវបានគេរួមបញ្ចូលជាវិស័យអាទិភាពមួយនៅក្នុងចំណោមគោលដៅទាំង ១៧ ចំនុចនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព

(Sustainable Development Goals)។ ហេតុដូចនេះ វិស័យទេសចរណ៍ទាមទារចាំបាច់ឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នៅក្នុងការអភិវឌ្ឍប្រកបដោយទំនួលខុសត្រូវខ្ពស់បំផុត។

នាពេលបច្ចុប្បន្ន ទេសចរណ៍គឺជាឧស្សាហកម្មនាំចេញធំជាងគេបំផុតទីបី នៅក្នុងពិភពលោកបន្ទាប់ពីឧស្សាហកម្មគីមី និងប្រេង។ ទេសចរណ៍នាំមកនូវក្តីសង្ឃឹម ភាពសម្បូរសប្បាយ និងការយោគយល់រវាងមនុស្ស និងមនុស្សនៅលើសាកលលោក។ ជាក់ស្តែងយោងតាមអង្គការទេសចរណ៍ពិភពលោក (UNWTO) នៅឆ្នាំ២០១៦ មានអ្នកដំណើរប្រមាណ១.២៣៥លាននាក់ ដែលធ្វើដំណើរឆ្លងកាត់ព្រំដែនអន្តរជាតិ ហើយចំនួននេះនឹងមានការកើនឡើងរហូតដល់ជាង១.៨០០លាននាក់ នៅមុនឆ្នាំ២០៣០។ ដើម្បីសម្រេចបាននូវកំណើនភ្ញៀវទេសចរចំនួន ១.៨០០លាននាក់នេះ យើងត្រូវផ្តោតលើ**យន្តការចូលរួមធ្វើឱ្យពិភពលោកក្លាយជាកន្លែងដែលកាន់តែប្រសើរឡើង និងឈានទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាពលើគ្រប់សសរគ្រឹះទាំង ៥៖ ១)សេដ្ឋកិច្ច៖** ការធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើន **២)សង្គម៖** នាំមកនូវការងារសមរម្យ និងការផ្តល់អំណាចដល់សហគមន៍ **៣)បរិស្ថាន៖** ការអភិរក្ស និងជួយទ្រទ្រង់ដល់បរិស្ថាន និងការទប់ស្កាត់នូវបម្រែបម្រួលអាកាសធាតុ **៤)វប្បធម៌៖** ការអបអរសាទរ និងការអភិរក្សភាពចំរុះ អត្តសញ្ញាណ និងវប្បធម៌រូបិយ និងអរូបិយ **៥)សន្តិភាព៖** ជាតម្រូវការចាំបាច់ជាមុនមួយសម្រាប់ការអភិវឌ្ឍ និងការរីកចម្រើន។

ជាការពិត វិស័យទេសចរណ៍ជាវិស័យដ៏សំខាន់សម្រាប់ពាណិជ្ជកម្មអន្តរជាតិ និងជាប្រភពចំណូលរូបិយប័ណ្ណបរទេស ដែលបានក្លាយជាកម្លាំងចលករក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ វិស័យទេសចរណ៍នៅកម្ពុជាជាទេសចរណ៍វប្បធម៌និងធម្មជាតិ ដែលបានរីកចម្រើនយ៉ាងខ្លាំងដោយរក្សាកំណើនថេរ រៀងរាល់ឆ្នាំ និងរួមចំណែកប្រមាណ១៣% នៃផលិតផលក្នុងស្រុកសរុបនៃសេដ្ឋកិច្ចជាតិ។

ដោយមើលឃើញអំពីសក្តានុពលទេសចរណ៍ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យទេសចរណ៍ជា "**មាសបៃតង**" ដែលចូលរួមអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន តាមរយៈការបង្កើតការងារដល់ប្រជាពលរដ្ឋកម្ពុជាផ្តល់ប្រាក់ចំណូលដល់ជាតិ ជំរុញការវិនិយោគ ផ្តល់អំណាចដល់សហគមន៍ អភិរក្សសម្បត្តិវប្បធម៌ជាតិ ថែរក្សាធម្មជាតិ ទប់ទល់បម្រែបម្រួលអាកាសធាតុ រក្សាវប្បធម៌ និងអត្តសញ្ញាណជាតិ រក្សាសន្តិភាព និងកាត់បន្ថយភាពក្រីក្រ ស្របតាមទស្សនទាន "**ទេសចរណ៍ដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីទេសចរណ៍**"។

ជាការពិត រាជរដ្ឋាភិបាលកម្ពុជាប្រកាន់ភ្ជាប់នូវទស្សនទានគន្លឹះ "**ការអភិវឌ្ឍទេសចរណ៍ដើម្បីជំរុញសេដ្ឋកិច្ច សង្គម និងបរិស្ថាន**" ដោយធានាថា កម្ពុជាមានសុខសន្តិភាព និងសុវត្ថិភាពពេញលេញសម្រាប់ការធ្វើដំណើរកម្សាន្តនៅទូទាំងប្រទេស។

ក្នុងន័យនេះ ដើម្បីចូលរួមអបអរសាទរទិវាទេសចរណ៍ពិភពលោកឆ្នាំ២០១៧ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមស្នើស្ថាប័នពាក់ព័ន្ធ វិស័យឯកជន សហគមន៍ទេសចរណ៍ ប្រជាពលរដ្ឋមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍ចូលរួមអភិវឌ្ឍទេសចរណ៍ឲ្យបានសកម្ម និងកាន់តែខ្លាំងក្លាថែមទៀត។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងទេសចរណ៍ជាសេនាធិការ បាននឹងកំពុងជំរុញទីផ្សារទេសចរណ៍ធុរកិច្ច ជំរុញចលនាទេសចរណ៍ក្នុងស្រុក អភិវឌ្ឍផលិតផលទេសចរណ៍ "**ខេត្តមួយ កញ្ចប់ទស្សនកិច្ចមួយ**" អភិវឌ្ឍ "**តំបន់មួយ ព្រឹត្តិការណ៍មួយ**" រៀបចំ**ទីផ្សារទេសចរណ៍យុវជន** (Youth Tourism) **ទីផ្សារទេសចរណ៍ទីក្រុង** (Urban Tourism) **និងទីផ្សារទេសចរណ៍ទិញទំនិញ** (Shopping Tourism)។

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំជឿជាក់ថា ទិវាទេសចរណ៍ពិភពលោកឆ្នាំ២០១៧ ក្រោមប្រធានបទ "**និរន្តរភាពទេសចរណ៍-ជាយន្តការសម្រាប់ការអភិវឌ្ឍន៍ (Sustainable Tourism- a Tool for Development)**" ជាឱកាសដ៏

វិសេសវិសាលមួយសម្រាប់លើកស្ទួយវិស័យទេសចរណ៍ ដែលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម អភិរក្សបរិស្ថាន កាត់បន្ថយភាពក្រីក្រ បង្កើនមិត្តភាព រក្សាសន្តិភាព និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រជាជាតិទាំងឡាយលើពិភពលោក ក្នុងការអភិវឌ្ឍទេសចរណ៍កម្ពុជា។

ឆ្លៀតឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់រូប ក្រសួងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ សូមបន្តចូលរួមគាំទ្រ និងរួមចំណែកឲ្យកាន់តែសកម្មក្នុងការអភិវឌ្ឍទេសចរណ៍កម្ពុជា តាមរយៈការថែរក្សាសម្បត្តិវប្បធម៌ រក្សាប្រពៃណីជាតិ ការពារបរិស្ថាន លើកកម្ពស់គុណភាពផលិតផល និងសេវាកម្មទេសចរណ៍ រក្សាសុខសន្តិភាព និងធានាសុវត្ថិភាពសម្រាប់ភ្ញៀវទេសចរ។

ជាមួយគ្នានេះ ខ្ញុំព្រះករុណាខ្ញុំ សូមលើកទឹកចិត្តស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន ចូលរួមឲ្យបានខ្លាំងក្លាក្នុងចលនាប្រឡងប្រណាំង **“ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ”** ដើម្បីឲ្យកម្ពុជាស័ក្តិសមជា **“ព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅដល់ភ្ញៀវទេសចរ** (Kingdom of Wonder- Feel the Warmth)” និងដើម្បីឲ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ ដ៏ទាក់ទាញមួយនៅក្នុងតំបន់ និងពិភពលោក។

ក្នុងឱកាសនេះដែរ ខ្ញុំព្រះករុណាខ្ញុំ សូមអញ្ជើញភ្ញៀវទេសចរអន្តរជាតិពីគ្រប់ទិសទីមកទស្សនាព្រះរាជាណាចក្រកម្ពុជាឲ្យកាន់តែច្រើន។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមឲ្យទិវាទេសចរណ៍ពិភពលោកឆ្នាំ២០១៧ ប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងសូមថ្វាយពរ និងប្រសិទ្ធពរជ័យដល់សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិទាំងអស់ ទទួលបានជោគជ័យក្នុងភារកិច្ចដ៏ឧត្តុង្គឧត្តម និងមានព្រះសុខភាព និងសុខភាពបរិបូណ៌។

*រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកញ្ញា ឆ្នាំ២០១៧*

**ហ៊ុន សែន**